CITY OF LONG BEACH

**Health and Human Services Department**
**Communicable Disease Surveillance and Control Division**
2525 Grand Ave. Long Beach, CA 90815
562.570.4302    FAX 562.570.4374

ថ្ងៃទី ២៩ ខែវិច្ឆិកា  ឆ្នាំ២០២១

ជូនចំពោះសិស្សានុសិស្ស និងក្រុមគ្រួសារនៃសិស្ស ប្រចាំសាលារៀនឡុងប៉ិច

នាយកដ្ឋានសុខាភិបាលរបស់ទីក្រុងឡុងប៉ិច សូមរំលឹកដល់សិស្សានុសិស្សនិងក្រុមគ្រួសាររបស់សិស្ស
នៃសាលារៀនឡុងប៊ិច អោយបន្តរួមចំណែកជួយការពារការរីករាលដាលជំងឺ កូវីដ-១៩
នៅតាមសាលារៀន។ ដោយរដូវកាលបុណ្យ និងរដូវរងា បានមកដល់
ដែលតម្រូវអោយយើងទាំងអស់គ្នាស្ថិតនៅក្នុងអាគារ
វាជាការសំខាន់ណាស់ដែលលោកអ្នកចងចាំនូវចំណុចខាងក្រោម
នៅពេលកូនរបស់លោកអ្នកត្រលប់ចូលរៀនវិញ។

1. អ្នករាល់គ្នា គួរតាមដានមើលអាការៈជារៀងរាល់ថ្ងៃ ហើយត្រូវសំរាកនៅផ្ទះបើមានអាការៈឈឺ។ ប្រសិនបើចេញរោគសញ្ញា ត្រូវធ្វើតេស្តអោយបានឆាប់បំផុត។ មានកន្លែងធ្វើតេស្តជាច្រើនកន្លែង ពាសពេញទីក្រុង (គេហទំព័រកន្លែងតេស្ត): https://www.longbeach.gov/health/diseases-and-condition/information-on/coronavirus/covid-19-testing/
2. ប្រសិនបើមាននណារម្នាក់នៅក្នុងផ្ទះមានភាពវិជ្ជមានជំងឺកូវីដ-១៩ ឬកូនរបស់អ្នកបាននៅជិតអ្នកដែលមានជំងឺកូវិដ-១៩ (ក្រៅពីពេលនៅសាលារៀន) វាជាការសំខាន់ណាស់ដែលកូនរបស់អ្នកមិនត្រូវទៅសាលារៀនឬចូលរួមសកម្មភាពនានាឡើយ រហូតទាល់តែកូនអ្នកធ្វើចត្តាឡីស័កអោយ បានគ្រប់ពេញលេញ (ការនៅដាច់ដោយឡែក) ។ សូមប្រាប់ព័ត៌មានពីការប៉ះពាល់នេះទៅសាលារៀនរបស់កូនអ្នកអោយបានឆាប់។
3. ប្រសិនបើកូនរបស់អ្នកមានភាពវិជ្ជមានជំងឺកូវីដ-១៩ អ្នកមិនចាំបាច់ធ្វើតេស្តឡើងវិញរហូតទាល់តែឃើញអវិជ្ជមានទេ លុះត្រាតែត្រូវបានគេប្រាប់ថាអោយធ្វើតេស្ត។ ការនៅដាច់ដោយឡែក ពីគេ ត្រូវបញ្ចប់ត្រឹមរយៈពេល១០ ថ្ងៃ  នៅពេលដែលអាការៈបានប្រសើរឡើង និងមិនមានការគ្រុនក្តៅក្នុងកំឡុងពេល២៤ម៉ោង ដោយមិនមានប្រើថ្នាំបាត់គ្រុន។ សូមផ្តល់លទ្ធផលតេស្តវិជ្ជមានទៅ ដល់សាលារៀនរបស់កូនអ្នកជាបន្ទាន់។
4. ថ្នាំបង្ការ (វ៉ាក់សាំង)នៅតែជាមធ្យោបាយដ៏ប្រសើរក្នុងការការពារជំងឺកូវីដ-១៩។ កុមារគ្រប់រូបដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ អាចទទួលថ្នាំវ៉ាក់សាំងកូវីដ-១៩ បាន។ សំរាប់ធ្វើការណាត់ចាក់ថ្នាំវ៉ាក់សាំង សូមចូលទៅគេហទំព័រ https://myturn.ca.gov/ ។

សូមអរគុណចំពោះការចូលរួមរបស់លោកអ្នកក្នុងការធ្វើអោយសាលារៀនយើងមានសុវត្ថិភាព !